ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងរដ្ឋប្បវេណីលេខ ១៨
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣
សញ្ញាណនៃរឿងក្តី លែងលះ
**សាលក្រមរដ្ឋប្បវេណី**
**លេខ ១១ "ឃ"/ ៨៩**
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

- បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង០៨និង៣០នាទីព្រឹក ក្នុងបន្ទប់សវនាការលេខ ខ.២ អាគារ ខ នៃសាលាដំបូងខេត្តសៀមរាប។

- កាលបរិច្ឆេទនៃការប្រកាសសាលក្រមនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០២និង៣០នាទីរសៀល នៅសាលាដំបូងខេត្តសៀមរាប។

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាអនុប្រធាន និងជាចៅក្រម សាលាដំបូងខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្ត

សាលាដំបូងខេត្តសៀមរាប បានចេញសាលក្រមដែលមានគូភាគីដូចខាងក្រោម៖

**ដើមចោទ៖** ឈ្មោះ [redacted] **សំណាង** ភេទស្រី កើតនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៩១ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅ[redacted]។

ដោយមានលោក [redacted] អត្តលេខ ២៥២៣T សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាននាមករណ៍ការិយាល័យក្រុមមេធាវី ស៊ី អេសអ៊ិន / C SN Law Group ស្នាក់ការតាំងនៅ[redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**ចុងចម្លើយ៖** ឈ្មោះ [redacted] **ឆៃណា** ភេទប្រុស កើតនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន[redacted]។

**កម្មវត្ថុនៃបណ្តឹង៖** ស្តីពីការឈប់រស់នៅតាមបែបអនីតិសង្វាស ការកំណត់អំណាចមេបា ការបែងចែកទ្រព្យសម្បត្តិ។

**អង្គហេតុ និងចំណុចវិវាទ**

**ក. ការទាមទាររបស់ភាគី ៖**

ដើមចោទទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖

១- ឲ្យដើមចោទឈ្មោះ [redacted] សំណាង ឈប់រស់នៅតាមបែបអនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] ឆៃណា។

២- ឲ្យដើមចោទឈ្មោះ [redacted] សំណាង ជាអ្នកមានអំណាចមេបាលើកូនៗចំនួន០២(ពីរ)នាក់ ដូចបញ្ជាក់អត្តសញ្ញាណខាងក្រោម៖



Scanned with CamScanner

- ឈ្មោះ [redacted] សិរីមង្គល ភេទប្រុស កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១។

- ឈ្មោះ [redacted] សិរីសក្កា ភេទប្រុស កើតថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៩។

៣- ការបែងចែកទ្រព្យសម្បត្តិដូចខាងក្រោម៖

៣.១- ប្រគល់ទ្រព្យសម្បត្តិដោយឡែក ដែលមានអត្តសញ្ញាណដូចខាងក្រោមឲ្យមកដើមចោទជាម្ចាស់កម្មសិទ្ធិតែម្នាក់ឯង៖

ក- ដីដែលមានក្បាលដីលេខ ១០៨១ ស្ថិតក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០១-១០៨១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ដែលមានទំហំ៧១៧ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងជាប់ក្បាលដីលេខ ៩៤៩ ខាងកើតជាប់ផ្លូវ ខាងត្បូងជាប់ក្បាលដីលេខ១០៨០ និងខាងលិចជាប់ក្បាលដីលេខ១១៥៩។

ខ- ដីដែលមានក្បាលដីលេខ ៤៨៨ ស្ថិតក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០១-០៤៨៨ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ដែលមានទំហំ៤១២ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងជាប់ក្បាលដីលេខ ៤៨១ ខាងកើតជាប់ក្បាលដី ៤៨៣ ខាងត្បូងជាប់ក្បាលដីលេខ ៤៨៣ និងខាងលិចជាប់ក្បាលដីលេខ ៥៣៣ និងក្បាលដីលេខ៤៨២។

៣.២- បែកចែកទ្រព្យសម្បត្តិរួមដែលមានអត្តសញ្ញាណដូចខាងក្រោម មកឲ្យដើមចោទ និងចុងចម្លើយជាពីរចំណែកតាមច្បាប់ គឺដីមួយកន្លែងមានសាលាកប័ត្រសម្រង់ព័ត៌មានប្លង់ក្បាលដីជាក់ស្តែង ចេញដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកបន្ទាយស្រី ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ មានទំហំសរុប១៨៨៨ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ស៊ីង ខាងត្បូងទល់នឹងឈ្មោះ [redacted] ជីវ ខាងកើតទល់នឹងឈ្មោះ [redacted] ស៊ីង និងខាងលិចទល់នឹងផ្លូវ ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

៤- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ខ. __ការពន្យល់ត្រួសៗអំពីរឿងក្តី៖__

ដើមចោទ និងចុងចម្លើយ បានរៀបការតាមប្រពៃណីនៅអំឡុងពីឆ្នាំ២០០៨ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ចាប់តាំងពីបានរួមរស់នៅជាមួយគ្នាមក ដើមចោទ និងចុងចម្លើយ មានកូនប្រុសពីរនាក់មានឈ្មោះ [redacted] សិរីមង្គល ភេទប្រុស កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ និងឈ្មោះ [redacted] សិរីសក្កា ភេទប្រុស កើតថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៩។ ចាប់តាំងពីដើមចោទ និងចុងចម្លើយបានរៀបការជាប្តីប្រពន្ធនឹងគ្នាមក ជីវិតគ្រួសារជួបតែការឈ្លោះប្រកែកគ្នា មិនសូវចុះសំរុងនឹងគ្នានោះទេ ចេះតែមានភាពរកាំរកូសនឹងគ្នាជានិច្ច ដោយសារចុងចម្លើយផឹកស៊ីស្រវឹងជេរប្រមាថដើមចោទ ថែមទាំងជេរប្រមាថឪពុកម្តាយបង្កើតដែលជាអ្នកមានគុណរបស់ខ្លួនមិនដែលលុះមួយពេលណាឡើយ តែខ្លួនចេះតែទ្រាំធ្វើម្តេចបើបានគ្នាជាប្តីប្រពន្ធទៅហើយ។ បើទោះបីជាមានការអភ័យទោសពីដើមចោទយ៉ាងណាក៏ដោយ ក៏ចុងចម្លើយមិនភ្ញាក់ខ្លួននោះដែរ ហើយក្រោយមកនៅអំឡុង២ឆ្នាំចុងក្រោយនេះ ចុងចម្លើយតែងតែទៅខេត្តឆ្ងាយៗបាត់ មិនដែលបានផ្តល់ប្រាក់កាសដើម្បីចិញ្ចឹមកូនៗ និងដើមចោទ

នោះទេ ហើយពេលមកផ្ទះម្តងៗដេរប្រមាថខ្លួន និងឪពុកម្តាយបង្កើតខ្លួនថែមទៀត។ លើសពីនេះ ចុងចម្លើយ និងដើមចោទក៏ពុំដែលបានផ្តល់ការរួមមេត្រីភាពជាប្តីប្រពន្ធដល់គ្នាផងដែរ។ ដោយពេលនេះ ដើមចោទ និងចុងចម្លើយ បានអស់មនោសញ្ចេតនាក្នុងការរួមរស់នៅជាមួយគ្នាជាស្វាមីភរិយានឹងគ្នាតទៅទៀតលែងបានក៏ប្តឹងមកតុលាការតែម្តង។

**គ.ចំណុចវិវាទនៃរឿងក្តី៖** ការកំណត់អំណាចមេបា និងបែងចែកដីមួយកន្លែងជាទ្រព្យរួម។

**ការអះអាងរបស់ភាគី**

(០១)- សេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] សំណាង និងមេធាវីតំណាងដោយអាណត្តិថា៖ ខ្លួន និងចុងចម្លើយបានរៀបការតាមប្រពៃណីនៅអំឡុងពីឆ្នាំ២០០៨ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ចាប់តាំងបានរួមរស់នៅជាមួយគ្នាមកខ្លួន និងចុងចម្លើយ មានកូនប្រុសពីរនាក់មានឈ្មោះ [redacted] សិរីមង្គល ភេទប្រុស កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ដែលមានសំបុត្រកំណើតលេខ១៦ ក្នុងសៀវភៅកំណើតលេខ០១/២០១១ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ជ្រាវ និងឈ្មោះ [redacted] សិរីសក្កា ភេទប្រុស កើតថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៩ ដែលមានសំបុត្របញ្ជាក់កំណើតលេខ២០២ ក្នុងសៀវភៅបញ្ជាក់កំណើតលេខ០៣/២០១៩ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ជ្រាវ។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នាខ្លួន និងចុងចម្លើយមានទ្រព្យសម្បត្តិរួមគ្នា តែដីមួយកន្លែងគត់គឺដីទំហំ១១ម៉ែត្រគុណនឹង១១០ ម៉ែត្រ ស្ថិតនៅភូមិរុន ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ចំណែកដីពីរកន្លែងផ្សេងទៀតនោះមានក្បាលដីលេខ១០៨១ ស្ថិតក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១៧១០០៦ ០១-១០៨១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ដែលមានទំហំ៧១៧ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងជាប់ ក្បាលដីលេខ៩៤៩ ខាងកើតជាប់ផ្លូវ ខាងត្បូងជាប់ក្បាលដីលេខ ១០៨០ និងខាងលិចជាប់ក្បាលដីលេខ១១៥៩ និងក្បាលដីលេខ៤៨៨ ស្ថិតក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១៧១ ០០៦០១-០៤៨៨ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ដែលមានទំហំ៤១២ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងជាប់ក្បាលដីលេខ៤៨១ ខាងកើតជាប់ក្បាលដី៤៨៣ ខាងត្បូងជាប់ក្បាលដីលេខ៤៨៣ និងខាងលិចជាប់ក្បាលដីលេខ៥៣៣ និងក្បាលដីលេខ៤៨២ គឺជាទ្រព្យដោយឡែករបស់ខ្លួនដែលបានទទួលអំណោយពីឪពុកម្តាយបង្កើតដើមចោទមកឲ្យខ្លួន។ ជាក់ស្តែងដូចមានបញ្ជាក់ក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៃទ្រព្យទាំងពីរភស្តុតាងតាំងស្រាប់។ ចាប់តាំងពីខ្លួន និងចុងចម្លើយបានរៀបការជាប្តីប្រពន្ធនឹងគ្នាមកជីវិតគ្រួសារជួបតែការឈ្លោះប្រកែកគ្នា មិនសូវចុះសម្រុងនឹងគ្នានោះទេ ចេះតែមានភាពរកាំរកូសនឹងគ្នាជានិច្ចដោយសារចុងចម្លើយផឹកស៊ីញឹកញាប់ អោយតែមិត្តភក្តិហៅផឹកគឺចេញទៅតែម្តង ហើយពេលត្រឡប់មកវិញស្រវឹងដេរជៀលខ្លួនដោយនិយាយថាង្កែងកាត់តាមឪតិរច្ឆានជាដើម និងដេរប្រមាថឪពុកម្តាយបង្កើត ដែលជាអ្នកមានគុណរបស់ខ្លួនមិនដែលលុះមួយពេលណាឡើយ តែខ្លួនចេះតែទ្រាំធ្វើម្តេចបើបានគ្នាជាប្តីប្រពន្ធទៅហើយ។ បើទោះបីជាមានការអភ័យទោសពីខ្លួនយ៉ាងណាក៏ដោយក៏ចុងចម្លើយមិនភ្ញាក់ខ្លួននោះដែរ ហើយក្រោយមកនៅអំឡុង០២ឆ្នាំ ចុងក្រោយនេះចុងខេត្តឆ្ងាយៗបាត់មិនដែលបាន

ផ្តល់ប្រាក់កាសដើម្បីចិញ្ចឹមកូនៗ និងខ្លួននោះទេ។ បច្ចុប្បន្នទំនាក់ទំនងមនោសញ្ចេតនាររបស់ខ្លួនមិនមានសម្រាប់ចុងចម្លើយទៀតទេ ហើយជាក់ស្តែងខ្លួន និងចុងចម្លើយបានលែងរួមសង្វាសជាមួយគ្នារស់នៅបែកបន្ទប់គ្នាអស់រយៈពេលជាងប្រាំមួយខែកន្លងមកហើយ។ ទំនាក់ទំនងមនោសញ្ចេតនារវាងខ្លួន ជាមួយចុងចម្លើយមិនអាចស្តារអោយល្អប្រសើរជាមួយគ្នាបានទេ។ ដោយមិនមានសង្ឃឹមថានឹងអាចរស់នៅមានសុភមង្គលជាមួយគ្នាបាននោះទេ។ ចុងចម្លើយមិនធ្លាប់ប្រើប្រាស់ហិង្សាលើខ្លួននោះឡើយ។ ទំនាក់ទំនងរវាងចុងចម្លើយជាមួយឪពុកបង្កើតរបស់ខ្លួនមិនត្រូវជាមួយគ្នានោះទេ។ សរុបមក ដើមចោទស្នើសុំតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ទុកនៅដដែរ គ្រាន់តែសុំកែតម្រូវត្រង់ចំណុចទី១ស្តីពីការទាមទារលែងលះ ដោយសុំកែតម្រូវទៅជាសុំឈប់រស់នៅតាមបែបអនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] ផែណា វិញ និងចំណុចទី៣ ស្តីពីការសុំទាមទារទ្រព្យសម្បត្តិដីពីរកន្លែងដូចក្នុងចំណុច ៣.១ សុំដកការទាមទារចោលវិញ ដោយសារចំណុច៣.១ (ដីពីរកន្លែងនេះ) ជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទជាកូនក្តីខ្លួនស្រាប់ទៅហើយ។ ក្រៅពីនេះសុំរក្សាទុកដូចក្នុងពាក្យបណ្តឹងដដែរ។ ចំពោះអង្គហេតុចាំបាច់ និងអង្គហេតុជាមូលហេតុនៃការទាមទារសុំរក្សាទុកដូចពាក្យបណ្តឹងដូចគ្នា។ ចំពោះកូនៗដើមចោទទាមទារ ដោយសារគាត់មានទីលំនៅច្បាស់លាស់ មានមុខរបរច្បាស់លាស់ មានឪពុកម្តាយនៅជាមួយជួយមើលថែរក្សាកូនៗផងដែរ។ កូនក្តីខ្លួនពិតជានិយាយថាបើចុងចម្លើយព្រមលែងលះដោយស្រួល កូនក្តីខ្លួននឹងមិនទាមទារបែកចែកដីនៅរុនតាឯកនោះទេ ហើយគាត់នៅតែរក្សាចំណុចនេះដដែរ។

(០២)- សេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយឈ្មោះ [redacted] ផែណា ថា៖ កាលពីនីតិវិធីត្រៀម "ចំពោះការទាមទារលែងលះ ខ្លួនមិនឯកភាពនោះទេ ព្រោះខ្លួននៅស្រឡាញ់ប្រពន្ធ និងកូនៗ។ ចំពោះមូលហេតុដែលដើមចោទលើកឡើងពីករណីផឹកស៊ី និងជេរជៀលគឺមានមែន តែម្តងម្កាលមិនញឹកញាប់នោះទេ។ ចំពោះសិទ្ធិអំណាចមេបាលើកូនៗទាំងពីរនាក់ ដែលដើមចោទទាមទារខ្លួនមិនឯកភាពនោះទេ ដោយខ្លួនក៏ទាមទារសិទ្ធិគ្រប់គ្រងកូនៗទាំងពីរនាក់នេះផងដែរ។ មូលហេតុដែលខ្លួនទាមទារសិទ្ធិលើកូនៗ ដោយសារខ្លួនគិតថាដើមចោទនឹងឆាប់មានដៃគូរថ្មី។ ចំពោះការទាមទារបែងចែកទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទលើដីពីរកន្លែងខ្លួនមិនតវ៉ាទេ តែចំពោះដីមួយកន្លែងនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ខ្លួនសុំទាមទារសិទ្ធិគ្រប់គ្រងលើដីនេះតែម្នាក់ឯង ដោយមិនបែងចែកជាពីរតាមការទាមទាររបស់ដើមចោទទេ ព្រោះដីនេះខ្លួនទៅទិញតែម្នាក់ឯង គ្រាន់តែចុះបញ្ជីដាក់ទ្រព្យជាមួយគ្នា ហើយខ្លួន និងដើមចោទក្នុងពេលរស់នៅជាមួយគ្នាក៏បានបន្សល់ទុកនូវសំណង់មួយចំនួននៅលើដីដែលជាទ្រព្យដោយឡែក ខាងដើមចោទផងដែរ ហេតុនេះ ការទាមទារដីមួយកន្លែងនៅភូមិតានីមកខ្លួនតែម្នាក់ឯងវាជារឿងត្រឹមត្រូវ។" នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចុងចម្លើយថា "ចំពោះទ្រព្យសម្បត្តិដោយឡែករបស់គាត់ទាំងពីរកន្លែងដែលឪពុកម្តាយគាត់ចែកអោយគាត់ ខ្លួនមិនជំទាស់នោះទេ តែចំពោះដីមួយកន្លែងនៅរុនតាឯក ពីមុនគាត់ថាបើខ្លួនព្រមលែងលះគាត់ដោយស្រួល គាត់មិនទាមទារបែងចែកដីនៅរុនតាឯកនោះទេ។ ហើយឥឡូវដើមចោទព្រមមិនទាមទារបែកចែកដីនៅរុនតាឯក ហេតុនេះ ខ្លួនក៏ព្រម

លែងលះជាមួយគាត់ដែរ។ តែចំពោះកូនៗ ខ្លួនសុំសិទ្ធិនៅពេលដែលគាត់មានប្តីក្រោយ ខ្លួនសុំសិទ្ធិគ្រប់គ្រងកូនៗវិញ ឬសិទ្ធទាមទារកូនៗមកគ្រប់គ្រងវិញ។

## សំអាងហេតុ

តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងពិនិត្យភស្តុតាងតុលាការយល់ឃើញថា៖

(០១)- ពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ [redacted] សំណាង ធ្វើឡើងត្រឹមត្រូវតាមមាត្រា ៧៥ សាលាដំបូងខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះក្តីយោងតាមមាត្រា៧ មាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(០២)- លក្ខណៈសម្បត្តិជាអ្នកតំណាងដោយអាណត្តិ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ របស់លោកស្រីមេធាវី [redacted] និងលោកមេធាវី [redacted] តំណាងដោយអាណត្តិឲ្យដើមចោទ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា៥២ មាត្រា៥៣ និងមាត្រា៥៤ ជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(០៣)- តាមសេចក្តីថ្លែងការណ៍របស់ភាគី និងភស្តុតាង តុលាការជឿជាក់ថាភាគីពិតជាបានរស់នៅជាមួយគ្នាបែបអនីតិសង្វាសតាំងពីឆ្នាំ២០០៨ និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាប្រាកដមែន តែទំនាក់ទំនងរវាងដើមចោទ និងចុងចម្លើយ មានលក្ខណៈដូចគ្នានឹងអាពាហ៍ពិពាហ៍ស្របច្បាប់ដែរ។ ជាមួយគ្នានេះ ដើម្បីជាប្រយោជន៍សម្រាប់ភាគីទាំងសង្ខាងក្នុងការដោះស្រាយវិវាទជាមួយគ្នាអោយបានឆាប់រហ័ស និងដើម្បីធានានូវសិទ្ធិពឹងពាក់តុលាការ ការទទួលខុសត្រូវរបស់តុលាការក្នុងការដោះស្រាយវិវាទអោយបានឆាប់រហ័ស គប្បីតុលាការលើកមកពិចារណានូវកម្មវត្ថុស្តីពីការសុំឈប់រស់នៅតាមបែបអនីតិសង្វាស ការកំណត់អំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិរបស់ភាគី។

(០៤)- យោងតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង ឃើញថារឿងក្តីនេះភាគីលែងមានវិវាទនឹងគ្នាហើយ ដោយភាគីទាំងសង្ខាងបានព្រមព្រៀងគ្នាដូចខាងក្រោម៖

- ភាគីទាំងសង្ខាងបានព្រមព្រៀងឈប់រស់នៅតាមបែបអនីតិសង្វាសពីគ្នា។ ទំនាក់ទំនងអនីតិសង្វាស ភាគីមានសេរីភាពពេញលេញក្នុងការបង្ហាញឆន្ទៈបញ្ឈប់ទំនាក់ទំនងនេះនៅពេលណាក៏បាន។ តែបើពិនិត្យលើចរិកលក្ខណៈនៃការបញ្ចប់ទំនាក់ទំនងអនីតិសង្វាសរបស់ភាគី តុលាការយល់ឃើញថាគប្បីលើកមកពិចារណាលើការទាមទារស្តីពីសុំឈប់រស់នៅតាមបែបអនីតិសង្វាសសម្រាប់ភាគី។

- ចុងចម្លើយថ្លែងការណ៍ថា នៅពេលដែលដើមចោទមានប្តីក្រោយ ចុងចម្លើយសុំសិទ្ធិគ្រប់គ្រងកូនៗវិញ ឬសិទ្ធទាមទារកូនៗមកគ្រប់គ្រងវិញ។ សេចក្តីថ្លែងការណ៍នេះ ស្របជាមួយឆន្ទៈភាគីចុងចម្លើយដោយទទួលយកដីក្នុងចំណុច៣.២ពីដើមចោទ ដើម្បីបញ្ចប់ការរស់នៅជាមួយគ្នាតាមបែបអនីតិសង្វាសដោយគ្មានវិវាទ។ យល់ឃើញថា ភាគីចុងចម្លើយមិនមានវិវាទពីការទាមទារសិទ្ធិអំណាចមេបាលើកូនៗទាំងពីរនាក់របស់ដើមចោទទេ។ តុលាការពិនិត្យឃើញថា ភាគីដើមចោទឈ្មោះ [redacted] សំណាង មានបុគ្គលិកលក្ខណៈល្អប្រសើរ ដែលអាចអនុវត្តសិទ្ធិជាអ្នកមានអំណាចមេបាលើកូនៗទាំងពីរនាក់អោយបានល្អផងដែរ ព្រោះដើមចោទជាអ្នកគ្រប់គ្រងកូនៗជាក់ស្តែង លក្ខណៈនៃការគ្រប់គ្រងនេះអាចបញ្ជាក់ថាកូនៗពិតជាមានមនោសញ្ចេតនាជិតស្និតជាមួយដើមចោទជាង។ ជាមួយគ្នានេះ ដើមចោទមានទីលំនៅច្បាស់លាស់ មានមុខរបរ មានឪពុកម្តាយអាចជួយមើលថែរក្សាកូនៗបន្ថែមទៀត។ លើសពីនេះ ការសិក្សារបស់កូនភាគីមានជីវភាពជុំវិញលំនៅដ្ឋានរបស់ដើមចោទ។ ហេតុនេះ ដោយគិតពី

ប្រយោជន៍របស់កូនៗ គប្បីតុលាការប្រគល់សិទ្ធិជាអ្នកមានអំណាចមេបាលើកូនៗទាំងពីរនាក់ឲ្យទៅដើមចោទជាអ្នកគ្រប់គ្រងតាមផ្លូវច្បាប់។

- ចំពោះចំណុចស្តីពីការបែងចែកទ្រព្យសម្បត្តិរួមគ្នា ឃើញថាភាគីដើមចោទបានដកនូវចំណុចនៃការទាមទារទ្រព្យសម្បត្តិក្នុងចំណុច៣.១ ហើយចំណុច៣.១នេះក៏មិនមែនជាចំណុចវិវាទនោះដែរ។ ហេតុនេះ តុលាការមិនពិចារណាលើការទាមទារត្រង់ចំណុចនេះទេ។ ភាគីដើមចោទស្នើសុំបែងចែកលើដីមួយកន្លែងត្រង់ចំណុច៣.២ គឺដីមួយកន្លែង មានសាលាកប័ត្រសម្រង់ពត៌មានប្លង់ក្បាលដីជាក់ស្តែង ចេញដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកបន្ទាយស្រី ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ មានទំហំសរុប១៨៨៨ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ស៊ីង ខាងត្បូងទល់នឹងឈ្មោះ [redacted] ជីវ ខាងកើតទល់នឹង ឈ្មោះ [redacted] ស៊ីង និងខាងលិចទល់នឹងផ្លូវ ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ តែចំណុច៣.២នេះ ក្រោយពីផ្សះផ្សារភាគីដើមចោទបានលះបង់ការទាមទាររបស់ខ្លួន ដោយប្រគល់ដីនេះអោយទៅចុងចម្លើយធ្វើលទ្ធកម្មតែម្នាក់ឯងវិញ ព្រោះចុងចម្លើយយល់ព្រមបញ្ចប់ការរស់នៅតាមបែបអនីតិសង្វាសដោយគ្មានវិវាទ។ ហេតុនេះ គប្បីសម្រេចប្រគល់សិទ្ធិលើអចលនវត្ថុនេះឲ្យទៅចុងចម្លើយតាមការព្រមព្រៀង។

យល់ឃើញថា ភាគីទាំងសង្ខាងបានព្រមព្រៀងគ្នាលើគ្រប់ចំណុចខាងលើ។ ការព្រមព្រៀងនេះគឺជាការព្រមព្រៀងដោយឆន្ទៈសេរី ពិតប្រាកដរបស់ភាគី ដោយមិនមានការបង្ខិតបង្ខំ និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ អនុលោមតាមគោលការណ៍ស្វ័យភាពឆន្ទៈរបស់បុគ្គលឯកជន គប្បីតុលាការសម្រេចតាមការព្រមព្រៀងទាំងអស់របស់ភាគីខាងលើ។

(០៥)- ចំពោះប្រាក់ប្រដាប់ក្តីតុលាការ និងការពន្ធលើពាក្យបណ្តឹង ដើមចោទទាមទារឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកបង់។ វិវាទនេះ ជាវិវាទបុគ្គលឯកជនក្នុងទំនាក់ទំនងឋានៈបុគ្គល ភាគីក៏បានព្រមព្រៀងគ្នាលើគ្រប់ចំណុច។ ហេតុនេះ គប្បីតុលាការសម្រេចឲ្យដើមចោទជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីតុលាការវិញ។

## សេចក្តីសម្រេចបញ្ចប់

១- ឲ្យដើមចោទឈ្មោះ [redacted] សំណាង ឈប់រស់នៅតាមបែបអនីតិសង្វាសពីចុងចម្លើយឈ្មោះ សៀ ឆៃណា តាមការព្រមព្រៀង។

២- ប្រគល់អំណាចមេបា (សិទ្ធិ និងករណីកិច្ចគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា អប់រំ មើលការខុសត្រូវលើកូនជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន) លើកូនៗចំនួនពីរនាក់មានឈ្មោះ [redacted] សិរីមង្គល ភេទប្រុស កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ និងឈ្មោះ [redacted] សិរីសក្តា ភេទប្រុស កើតថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៩ ឲ្យទៅដើមចោទឈ្មោះ [redacted] សំណាង ។

៣- ឲ្យចុងចម្លើយឈ្មោះ [redacted] ឆៃណា ជាឪពុកមានសិទ្ធិចូលជួប សួរសុខទុក្ខ អប់រំកូនៗបានជាធម្មតាក្នុងពេលវេលាសមរម្យដោយគិតពិចារណាលើផលប្រយោជន៍កូនៗ។ ដើមចោទជាម្តាយត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ទំនាក់ទំនងនេះស្របតាមមាត្រា១០៤០នៃក្រមរដ្ឋប្បវេណី។

៤- ប្រគល់ដីមួយកន្លែង មានសាលាកប័ត្រសម្រង់ពត៌មានប្លង់ក្បាលដីជាក់ស្តែង ចេញដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកបន្ទាយស្រី ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ មានទំហំសរុប១៨៨៨ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ស៊ីង ខាង



Scanned with CamScanner

ត្បូងទល់នឹងឈ្មោះ [redacted] ជីវ ខាងកើតទល់នឹង ឈ្មោះ [redacted] ស៊ឹង និងខាងលិចទល់នឹងផ្លូវ ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ឲ្យទៅចុងចម្លើយឈ្មោះ [redacted] ផៃណា តែម្នាក់ឯង។

៥- ឲ្យដើមចោទជាអ្នកទទួលបន្ទុកបង់ពន្ធ និងប្រាក់ប្រដាប់ក្តីតុលាការតាមការទាមទារ៕

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

សៀមរាប, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]